ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ✓ មស.

# សាររំលែកទុក្ខ

**សូមគោរពជូន**

**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និង សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងក្រុមគ្រួសារ**

**សម្ដេចជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ មានក្ដីរន្ធត់ និងសោកស្ដាយជាទីបំផុត នៅពេលបានទទួលដំណឹងថា **លោកជំទាវ ប៊ុន សុថា** ហៅ **ប៊ុន សាមហ៊ីង** ដែលត្រូវជាប្អូនស្រី **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ទទួលមរណភាព កាលពីថ្ងៃសុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ១៨:១៣នាទី ក្នុងជន្មាយុ ៦៧ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសប្រកបដោយក្ដីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ យើងខ្ញុំសូមចូលរួមសម្ដែងនូវមរណទុក្ខ និងសោកស្ដាយយ៉ាងខ្លាំងបំផុតជាមួយ **សម្ដេច** ព្រមទាំងក្រុមគ្រួសារ និងសាច់សារលោហិតទាំងអស់ ចំពោះមរណភាព **លោកជំទាវ ប៊ុន សុថា** ហៅ **ប៊ុន សាមហ៊ីង** ដែលជាការបាត់បង់ដ៏ធំធេង មិនអាចរកអ្វីមកប្រៀបផ្ទឹមបានឡើយ។ មរណភាព **លោកជំទាវ** គឺជាការបាត់បង់នូវប្អូនស្រី ឧត្ដមភរិយា មាតា មាតាក្មេក និងជីដូនជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតរបស់កូនៗ ក្មួយៗ និងចៅៗគ្រប់រូប ដែលកន្លងមក **លោកជំទាវ** បានពុះពារចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់ផ្ដង់ទំនុកបម្រុងសព្វបែបយ៉ាងដល់ក្រុមគ្រួសារ កូនៗ ចៅៗ ជាមួយការអប់រំ ទូន្មាន និងសេចក្ដីស្រឡាញ់ដ៏ធំធេងរកអ្វីមកប្រៀបផ្ទឹមពុំបាន រហូតធ្វើឱ្យកូនៗ ចៅៗបានក្លាយជាបញ្ញាវន្ត និងជាពលរដ្ឋល្អរបស់សង្គមជាតិ។

យើងខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ **លោកជំទាវ ប៊ុន សុថា** ហៅ **ប៊ុន សាមហ៊ីង** បានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** និង**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** មេត្តាទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ។

ថ្ងៃ សុក្រ ១៣ កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

រដ្ឋមន្ត្រី

ព្រុំ សុខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកទុក្ខ

**ជូនចំពោះ**
**ឯកឧត្តម តាន់ បញ្ញារុធ និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់មានក្តីរន្ធត់ និងសោកស្តាយជាពន់ពេក ដោយទទួលដំណឹងថា **លោកជំទាវ ម៉ុន សុថា** ហៅ **ម៉ុន សាមហ៊ឹង** ដែលត្រូវជាភរិយារបស់ **ឯកឧត្តម** បានទទួលមរណភាព កាលពីថ្ងៃសុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈឆ្នាំ២០២៣ វេលាម៉ោង ១៨:១៣នាទី ក្នុងជន្មាយុ ៦៧ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាទីបំផុតជាមួយ **ឯកឧត្តម និងក្រុមគ្រួសារ** ចំពោះការបាត់បង់ដ៏ធំធេងមិនអាចរកអ្វីមកប្រៀបបានមួយនេះ។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ **លោកជំទាវ ម៉ុន សុថា** ហៅ **ម៉ុន សាមហ៊ឹង** បានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម និងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ។

ថ្ងៃ សុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រំ សុខា